# ទំនុកដំកើង ១២៦

អ្នកនិពន្ធ រុហ្វ លេភិឡារ

**ទំនុកដំកើង ១២៦-១២៨។ ក្រុមទីបីដែលមានទំនុកដំកើងបី (សូមមើលការនែនាំសំរាប់ទំនុកដំកើង ១២០-១៣៤)។**

ទំនុកដំកើង ១២៦ ដែលជាទំនុកដំកើងទីមួយនៅក្នុងក្រុមនេះ បង្ហាញថាប្រជារាស្ត្ររបស់ព្រះនៅតែជួបប្រទះទុក្ខលំបាកហើយអាចមាន*ទឹកភ្នែក* (១២៦:៥) នៅឡើយ។ ប៉ុន្តែទំនុកដំកើង ១២៧ ដែលជាទំនុកដំកើងទីពីរ បង្ហាញថានៅក្នុង*ការធ្វើការនឿយហត់* (១២៧:២) នៃជីវិត ព្រះអម្ចាស់ប្រទានការដេកលក់ (១-២) ហើយទឹកភ្នែកនៅចុងទំនុកដំកើង ១២៦ ត្រឡប់ជា «សប្បាយ» (*ទទួលព្រះពរ*) នៅក្នុង១២៧:៥។ ទំនុកដំកើង ១២៨ ដែលជាទំនុកដំកើងទីបីនៅក្នុងក្រុមនេះ បញ្ជាក់អំពីសេចក្តីសុខសប្បាយ (១ *មានពរ* ២ *ព្រះពរ* «ឯងនឹងបានសប្បាយ») ដែលបានមកតាមរយៈព្រះពររបស់ព្រះ (៤-៥)។ ដូច្នេះ ផ្ទៃរឿងនៅក្នុងក្រុមដែលមានទំនុកដំកើងបីនេះខុសគ្នាពីផ្ទៃរឿងអំពី «ការទៅឯស៊ីយ៉ូន» របស់ពីរក្រុមដំបូង (១២០-១២២, ១២៣-១២៥។ នៅក្នុងគំនិតមួយ ក្រុមនេះ (ទំនុកដំកើង ១២៦-១២៨) ចាប់ផ្តើមនៅក្នុងស៊ីយ៉ូន (១២៦) ហើយបញ្ចប់នៅទីនោះ (១២៨)។ ប៉ុន្តែវាចាប់ផ្តើមនៅក្នុងទំនុកដំកើង ១២៦ ដោយការសំឡឹងទៅអនាគតដោយសេចក្តីសង្ឃឹមសំរាប់ព្រះពរដែលពួកគេមិនមាននាពេលបច្ចុប្បន្ន ហើយបញ្ចប់នៅក្នុងទំនុកដំកើង ១២៨ ដោយមនុស្សកំពុងរីករាយពីព្រោះគេបានទទួលព្រះពរពីព្រះ។ ដូច្នេះ ក្រុមដែលទំនុកដំកើងបីនេះគឺដូចជាធម្មយាត្រានៃចិត្តជាជាងធម្មយាត្រានៃជើង គឺជាការចង់បានព្រះពរធំជាងព្រះពរដែលយើងមានក្នុងពេលបច្ចុប្បន្ន (១២៦) ហើយនិងសន្តិភាពធំជាងសន្តិភាពដែលយើងមានក្នុងពេលបច្ចុប្បន្ន (១២៧)។

**ទំនុកដំកើង ១២៦**

ទំនុកដំកើងនេះចែកជាពីរផ្នែកយ៉ាងច្បាស់លាស់ គឺខ.១-៣ និងខ. ៤-៦។ ផ្នែកទាំងពីរនេះមានរចនាសម្ព័ន្ធស្រដៀងគ្នា គឺពួកវាចាប់ផ្តើមដោយការនិយាយអំពីការស្តារឡើងវិញ (១, ៤) ហើយបន្ទាប់មកនិយាយអំពីអំណរ (២, ៣, ៥, ៦)។

***១២៦:១-៣ ពួកគេនឹកចាំអំពីអំណរនៅក្នុងអតីតកាល***

ពាក់កណ្តាលដំបូងនៃទំនុកដំកើងបញ្ជាក់អំពីអំណរដ៏ធំដោយព្រោះព្រះយេហូវ៉ាបានស្តារប្រជារាស្ត្រឲ្យទៅកាន់ស៊ីយ៉ូន (យេរូសាឡឹម) វិញ។ ការស្តារឡើងវិញដ៏អស្ចារ្យនេះត្រូវបានប្រកាសក្នុងចំណោមជាតិសាសន៍ទាំងអស់។ ទោះយ៉ាងណា អំណរដែលបានបរិយាយនោះមិនមែនជាបទពិសោធន៍នាពេលបច្ចុប្បន្នរបស់បណ្តាជននោះទេ។ ខគម្ពីរទាំងនេះគឺកំពុងនឹកចាំអំពីអំណរនិងសំណើចនៅក្នុងកំឡុងពេលមុននេះ ហើយបន្ទាប់មកនៅក្នុងខ. ៤-៦ យើងមានការពិពណ៌នាអំពីបទពិសោធន៍នាពេលបច្ចុប្បន្នរបស់ពួកគេ។

***១២៦:៤-៦ សេចក្តីអធិស្ឋានសំរាប់ការស្តារឡើងវិញ***

បទពិសោធន៍នាពេលបច្ចុប្បន្នគឺជា*ទឹកភ្នែក* (ខ. ៤) ហើយនិង*យំ* (ខ. ៦)។ ការនឹកចាំអំពីអ្វីដែលព្រះបានធ្វើនៅក្នុងអតីតកាល (ខ. ១-៣) ប្រទានសេចក្តីសង្ឃឹមដែលថាព្រះអាចធ្វើការស្តារប្រជារាស្ត្ររបស់ទ្រង់ម្តងទៀត។ ដូច្នេះ ខ. ៤គឺជាសេចក្តីអធិស្ឋានមួយដើម្បីឲ្យព្រះស្តារពួកគេ*ដូចជាទឹកជ្រោះនៅស្រុកខាងត្បូង*។ ប្រជាជនកម្ពុជាស៊ាំថ្មីកទៅនឹងរដូវវស្សានិងរដូវប្រាំង។ នៅចុងបញ្ចប់រដូវប្រាំងវាលស្រែទាំងឡាយមានពណ៌ត្នោត។ ប៉ុន្តែនៅពេលភ្លៀងធ្លាក់មក វាលស្រែទាំងនោះត្រឡប់ជាមានពណ៌បៃតង។ ពាក្យប្រៀបនៅក្នុងខ.៤ ទាក់ទងនឹង*ទឹកជ្រោះនៅស្រុកខាងត្បូង* (ភាសាហេព្រើរអានថា *ទឹកជ្រោះនៅស្រុកណេគិប* בַּנֶּגֶב Negev)មានលក្ខណៈខ្លាំងជាង។ ជ្រលងភ្នំនៃប៉ាឡេស្ទីនមានទឹកបន្តិចបន្តួចឬគ្មានទឹកតែម្តងនៅក្នុងរដូវក្តៅ វាគឺជាទន្លេដែលគ្មានទឹក។ ទោះយ៉ាងណា ជ្រលងភ្នំទាំងនោះអាចត្រឡប់ជាទន្លេដែលមានទឹកហូរហៀរ ជាជ្រោះដែលមានទឹកច្រើននៅក្នុងរដូវវស្សា។ នៅស្រុកខាងត្បូង(ស្រុកណេគិប)ដែលជាតំបន់វាលរហោស្ថានហួតហែងនៅខាងត្បូងយេរូសាឡឹម កំឡុងពេលមានទឹកជំនន់នៅជ្រលងភ្នំទាំងនេះបាននាំមកនូវទឹកជំនន់មួយ

រំពេច ដែលផ្លាស់ប្តូរផ្លូវទឹកដែលស្ងួតហែងនិងធ្វើឲ្យដីដែលឆេះក្រៀមក្លាយទៅជាសួនច្បារមួយដែលនាំមកនូវភាពធូរស្រាលនិងជីវិត។ នៅក្នុងខ. ៤ អ្នកនិពន្ធបានអង្វរព្រះអង្គសូមឲ្យទ្រង់ស្តាររាស្ត្ររបស់ព្រះឡើងវិញដូចទឹកជ្រោះនៅស្រុកណេកិបក្នុងរដូវវស្សា។

នៅពេលព្រះធ្វើការជាថ្មីដូចនេះ នោះមិនមានន័យថាមនុស្សនឹងមិនចាំបាច់ធ្វើការងារទៀតនោះទេ គឺយើងនៅតែត្រូវព្រោះនិងច្រូតកាត់ដដែល (ខ. ៥-៦) ទោះយ៉ាងណា ជំនួសឲ្យការងាររបស់យើងដែលពោរពេញទៅដោយទឹកភ្នែកដោយព្រោះយើងមិនបានទទួលផល នៅពេលព្រះស្តារពួកគេឡើងវិញ ការងារនោះនឹងបានពេញដោយចម្រៀងអរសប្បាយវិញ (ខ. ៥, ៦)។

**ការអនុវត្ត**

ព្រះគឺជាព្រះមួយអង្គដែលរីករាយជាមួយនឹងការប្រទានព្រះពរដល់ប្រជារាស្ត្ររបស់ទ្រង់ ហើយយើងគួរតែមានអំណរនៅក្នុងព្រះពរដែលទ្រង់ប្រទានឲ្យ។ ទោះយ៉ាងណា ម្តងទៀតយើងឃើញថាបទពិសោធន៍របស់យើងគឺថា ជីវិតមិនតែងតែមានភាពងាយស្រួលនោះទេ ប៉ុន្តែការនេះគួរតែដឹកនាំយើងឲ្យអធិស្ឋានទៅចំពោះព្រះហើយរង់ចាំទ្រង់ដោយអត់ធ្មត់។ ថ្វីបើទ្រង់ប្រទានពរ នោះមិនមានន័យថាយើងមិនធ្វើការងារនោះទេ ប៉ុន្តែព្រះប្រទានព្រះពរនៅក្នុងការងាររបស់យើង។ ដូចដែលទំនុកដំកើងនេះបញ្ជាក់អំពីការនឹកចាំរបស់សាសន៍អ៊ីស្រាអែលអំពីអ្វីដែលព្រះបានធ្វើនៅក្នុងអតីតកាលដែលបាននាំពួកគេឲ្យអធិស្ឋានដោយទំនុកចិត្តនិងរង់ចាំព្រះធ្វើការធំជាងនេះនៅក្នុងពេលអនាគត ពួកគ្រីស្ទបរិស័ទក៏គួរតែនឹកចាំដោយអំណរនូវអ្វីដែលព្រះបានធ្វើកាលពីជាង២០០០ឆ្នាំមុនដើម្បីប្រោសលោះយើងតាមរយៈដំណឹងល្អរបស់ព្រះគ្រីស្ទ ហើយការនឹកចាំអំពីការសុគតនិងការរស់ឡើងវិញរបស់ព្រះយេស៊ូវនាំឲ្យយើងរង់ចាំដោយអត់ធ្មត់ដល់ការសន្យាវិលត្រឡប់មកវិញរបស់ព្រះយេស៊ូវក្នុងពេលអនាគត។ ដូច្នេះ យ៉ាកុបក៏បានប្រើពាក្យប្រៀបអំពីកសិករម្នាក់កំពុងរង់ចាំដោយអត់ធ្មត់សំរាប់ការច្រូតកាត់ដើម្បីលើកទឹកចិត្តពួកគ្រីស្ទបរិស័ទឲ្យរង់ចាំការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទដោយអំណត់ផងដែរ (យ៉ាកុប ៤:៧-៨)។

## Bibliography


*Biblia Hebraica Stuttgartensia: With Westminster Hebrew Morphology.* 1995. Stuttgart; Glenside PA: German Bible Society; Westminster Seminary.

Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.) Leicester, England; Downers Grove, IL: Inter-Varsity Press.

Henry, M. (1994), *Matthew Henry's commentary on the whole Bible: Complete and unabridged in one volume*, Peabody: Hendrickson.

Kidner, D. (1975). *Vol. 16*: *Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries (465–467). Nottingham, England: Inter-Varsity Press.

Matthews, V. H., M. W. Chavalas & J.H. Walton (2000), *The IVP Bible background commentary: Old Testament*, Downers Grove, IL: InterVarsity Press.

Wilcock, Michael. (2001), *The Message of Psalms 73-150.* The Bible Speaks Today Commentaries. Leicester, England: Inter-Varsity Press.